ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលជលផល
ក្រុមការងារច្បាប់នៃរដ្ឋបាលជលផល

ឯកសារបណ្តុះបណ្តាល

# ច្បាប់ ស្តីពី ជលផល

រៀបរៀងដោយៈ

ឯកឧត្តម ណៅ ធួក "ប្រធានរដ្ឋបាលជលផល"
លោក លី វុទ្ធី "ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍"
លោក សំ សត្យា "មន្ត្រីការិយាល័យវិវាទ"

ខែ តុលា ឆ្នាំ ២០០៦

រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា

ឈ្មោះ ទំព័រ

សេចក្តីផ្តើម:........................................................................................................ ១

ជំពូក ១: អំពីរដ្ឋបាលជលផល និងការគ្រប់គ្រងជលផល........................................................... ២

១. រចនាសម្ព័ន្ធរដ្ឋបាលជលផល..................................................................................... ២

២. ការគ្រប់គ្រងដោយគោលនយោបាយវិស័យជលផលជាតិ...................................................... ២

៣.តំបន់គ្រប់គ្រងជលផល............................................................................................. ៣

៤. អំពីដែននេសាទ និងការគ្រប់គ្រងដែននេសាទ................................................................ ៣

៤.១ និយមន័យដែលនេសាទ.......................................................................................... ៣

ក. ដែននេសាទទឹកសាប.............................................................................................. ៤

ខ. ដែននេសាទសមុទ្រ................................................................................................ ៤

៤.២. ការគ្រប់គ្រងអាជីវកម្ម........................................................................................... ៥

ក. ឧបករណ៍នេសាទ................................................................................................... ៥

ខ. ការធ្វើអាជីវកម្មនេសាទ.......................................................................................... ៥

៤.៣. ការគ្រប់គ្រងនាទីព្រៃលិចទឹក និងព្រៃកោងកាង........................................................ ៧

ជំពូក ២: សហគមន៍នេសាទ............................................................................................ ៨

១. និយមន័យ:........................................................................................................... ៨

២. វិធាននៃការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ...................................................... ៨

២.១ លក្ខខណ្ឌនៃការបង្កើតសហគមន៍នេសាទ..................................................................... ៨

ក. អំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង.............................................................................. ៨

ខ. កិច្ចព្រមព្រៀង និងផែនទីសហគមន៍នេសាទ.................................................................. ៩

គ. អំពីផែនការគ្រប់គ្រងសហគមន៍នេសាទ........................................................................ ១០

២.២. លក្ខខណ្ឌសុំចូលជាសមាជិក សិទ្ធិ និងតួនាទីភារកិច្ចរបស់សមាជិកសហគមន៍នេសាទ.................១១

ក.លក្ខខណ្ឌសុំចូលជាសមាជិកសហគមន៍នេសាទ................................................................ ១១

ខ. សិទ្ធិ និងតួនាទីភារកិច្ចរបស់សមាជិកសហគមន៍នេសាទ.................................................... ១១

គ. សិទ្ធ និងតួនាទីភារកិច្ចរបស់សហគមន៍នេសាទ............................................................... ១២

គ.១. សិទ្ធិសហគមន៍នេសាទ............................................................................................ ១២

គ.២. តួនាទី ភារកិច្ចរបស់សហគមន៍នេសាទ............................................................ ១៣

ឃ.ការជ្រើសរើសប្រធាន និងគណៈកម្មការសហគមន៍នេសាទ........................................ ១៣

ឃ.១. ការជ្រើសរើសគណៈកម្មការសហគមន៍នេសាទ................................................ ១៤

ឃ.២. ការជ្រើសរើសប្រធានគណៈកម្មការសហគមន៍នេសាទ.......................................... ១៤

៣. ស្ថាប័នគ្រប់គ្រង និងប្រភពថវិការបស់សហគមន៍នេសាទ.................................................. ១៤

៣.១. ស្ថាប័នគ្រប់គ្រង .................................................................................... ១៤

ក. តួនាទី និងភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ................................ ១៤

ខ. តួនាទី និងភារកិច្ចរបស់រដ្ឋបាលជលផល................................................................ ១៥

៣.២. ប្រភពថវិការបស់សហគមន៍នេសាទ..................................................................... ១៥

ជំពូក ៣: ការគ្រប់គ្រងវារីវប្បកម្ម ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល............ ១៧

១. ការគ្រប់គ្រងវារីវប្បកម្ម.............................................................................................១៧

ក. ការគ្រប់គ្រងវារីវប្បកម្មទឹកសាប................................................................................ ១៧

ខ. ការគ្រប់គ្រងវារីវប្បកម្មសមុទ្រ................................................................................... ១៧

២. ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល............................................ ១៨

៣. អំពីបរិស្ថាន ការនាំចូលវារីរុក្ខជាតិ វារីសត្វពីបរទេស និងការចេញលិខិតអនុញ្ញាត.................... ១៨

ជំពូក ៤: នីតិវិធីដោះស្រាយបទល្មើសជលផល..................................................................២០

១. ដំណោះស្រាយបទល្មើសជលផលដោយរដ្ឋបាលជលផល.................................................. ២០

១.១. អំពីមន្ត្រីនគរបាលយុត្តិធម៌ជលផល.................................................................. ២១

១.២. ការចងក្រងសំណុំរឿងសម្រាប់ពិន័យអន្តរការណ៍....................................................... ២២

២. ដំណោះស្រាយបទល្មើសជលផលដោយតុលាការ........................................................... ២៣

ក. អំពីអយ្យការអមតុលាការ ខេត្ត/ក្រុង.......................................................................... ២៤

ខ. អំពីចៅក្រមស៊ើបអង្កេត ឬ សុភាចារបុរស .................................................................. ២៥

គ. អំពីចៅក្រមជំនុំជម្រះ....................................................................................... ២៦

៣.សមត្ថកិច្ចពាក់ព័ន្ធ និងការអនុវត្តសាលក្រម ឬ សាលដីកា.................................................. ២៦

៣.១. សមត្ថកិច្ចពាក់ព័ន្ធ........................................................................................ ២៦

៣.២. ការអនុវត្តសាលក្រម ឬ សាលដីកា....................................................................... ២៧

# សេចក្តីផ្តើម

ច្បាប់ស្តីពីជលផល គឺជាវិធានគតិយុត្តិមួយសម្រាប់គ្រប់គ្រង និងការពារនូវធនធានជលផលធម្មជាតិ ក៏ដូចធនធានកែច្នៃ ការដឹកជញ្ជូនជលផល ការទិញ-លក់ ការអភិរក្ស ការការពារ ការថែរក្សាព្រៃលិចទឹក...ព្រមទាំងអាជ្ញាធររដ្ឋបាលជលផល ដែលស្ថិតក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមត្ថកិច្ច*ទទួលបន្ទុក* ។

ច្បាប់ស្តីពីជលផលត្រូវបានព្រាង និងរៀបចំឡើងដំបូងដោយបណ្ឌិតច្បាប់នៃធនាគារពិភពលោក រួមជាមួយគណៈកម្មាការបច្ចេកទេសជលផលនៅ ឆ្នាំ១៩៩៩ ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានធ្វើការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងច្រើនដង ដើម្បីធ្វើការកែលំអឱ្យបានសមស្របតាមការវិវឌ្ឍន៍របស់សង្គមកម្ពុជា ក៏ដូចជាឱ្យស្របតាមគោលការណ៍ច្បាប់ ប្រពៃណីទំនៀមទំលាប់ ជាពិសេសចំពោះអ្នកនេសាទ អ្នកចិញ្ចឹមត្រី ឬពាណិជ្ជករត្រី ។ល។ ជាមួយគ្នានេះដែរ សេចក្តីព្រាងច្បាប់ស្តីពីជលផលក៏ត្រូវបានការផ្តល់នូវអនុសាសន៍ល្អៗមួយចំនួនអំពីអាជ្ញាធរដែនដី ក្រសួងពាក់ព័ន្ធ សង្គមស៊ីវិល ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រី កិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី ហើយនៅថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៦ ត្រូវបានសភាពេញអង្គអនុម័ត។ បន្ទាប់មកទៀត នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។

## ជំពូក ១

# ទំពីរដ្ឋបាលជលផល និងការគ្រប់គ្រងជលផល

មុននឹងសិក្សាច្បាប់ស្តីពីជលផល យើងគប្បីស្វែងយល់ពាក្យ **រដ្ឋបាលជលផល** ជាមុនសិន។ រដ្ឋបាលជលផលផ្សំឡើងពីពាក្យ "*រដ្ឋបាល* និង *ជលផល*"។

**រដ្ឋបាល** = ការថែរក្សារដ្ឋ នគរ ឬ ប្រទេស

**ជលផល** = សំដៅប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិត ក្រោមទម្រង់ជាដីលិចទឹកដែលគ្របដណ្តប់ទៅដោយទឹកអចិន្ត្រៃយ៍ ឬ ជំនោរឡើង ឬ ទឹកជោរ នាច និងរុក្ខជាតិចម្រុះលិចទឹក ព្រមទាំងធនធានជីវសាស្ត្រដូចជា វារីសត្វ វារីរុក្ខជាតិដែលបង្កកំណើតនៅក្នុងទឹក ។ ចំពោះពាក្យរដ្ឋបាលខាងលើ ហាក់សំដៅតែទៅលើ រដ្ឋបាលសាធារណៈមួយប៉ុណ្ណោះ ( កិច្ចការរដ្ឋ ) ។ ប៉ុន្តែការអនុវត្តជាក់ស្តែង ក្នុងវិស័យឯកជនដូចជា: ក្រុមហ៊ុនសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក៏មានរដ្ឋបាលរបស់គេដែរ ។

ដើម្បីឱ្យពាក្យរដ្ឋបាលមានន័យរួម និងជាពិសេសបានត្រឹមត្រូវតាមន័យនីតិរដ្ឋបាលនោះ ពាក្យរដ្ឋបាលមានន័យថា : "*សកម្មភាពគ្រប់គ្រង*"។

ដូច្នេះ "*រដ្ឋបាលជលផលមានន័យថា ជាសកម្មភាពគ្រប់គ្រងធនធានជលផល ក្នុងនោះ រួមមានធនធានជលផលធម្មជាតិ ធនធានជលផលសិប្បនិម្មិតទាំងទឹកសាប ទាំងសមុទ្រ រួមទាំងការដឹកជញ្ជូនជលផល និងការគ្រប់គ្រងដែននេសាទផងដែរ*" ។

### ១. រចនាសម្ព័ន្ធរដ្ឋបាលជលផល

រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ( មាត្រា ៦ ច្បាប់ស្តីពីជលផល ២០០៦) ។

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

### ២. ការគ្រប់គ្រងដោយគោលនយោបាយវិស័យជលផលជាតិ

ដើម្បីគ្រប់គ្រងវិស័យជលផលប្រកបដោយនិរន្តរភាព ច្បាប់ស្តីពីជលផលតម្រូវឱ្យមានគោលនយោបាយវិស័យជលផលជាតិ មានគណៈកម្មាធិការគ្រប់គ្រងដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមានសមាជិកមួយចំនួនមកពីក្រសួងពាក់ព័ន្ធ ( មាត្រា ១៤ ច្បាប់ស្តីពីជលផល ២០០៦) ។

លើសពីនេះទៅទៀត រដ្ឋបាលជលផលត្រូវរៀបចំផែនការគ្រប់គ្រងវិស័យជលផលជាតិ ស្របតាមគោលនយោបាយវិស័យជលផលជាតិ ហើយផែនការនេះតម្រូវឱ្យមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។ ផែនការ តម្រូវឱ្យធ្វើការពិនិត្យ និងសើរើរៀងរាល់ប្រាំឆ្នាំ (៥) ម្តងដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យជលផលជាតិ ត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យជលផលជាតិដែលបានសើរើ ( មាត្រា ១៥ ច្បាប់ស្តីពីជលផល ២០០៦ ) ។

រដ្ឋបាលជលផល ត្រូវទទួលបាននូវថវិកាអំពីចំណូលលើវិស័យជលផល ជាអទិភាពតាមនីតិវិធីហិរញ្ញវត្ថុ សម្រាប់បំរើឱ្យការងារកែទម្រង់វិស័យជលផលដូចជា ការស្រាវជ្រាវ ការអភិរក្ស និងការថែរក្សាធនធានជលផលប្រកបដោយនិរន្តរភាព។

ច្បាប់ស្តីពីជលផល បានបង្កើតឡើងនូវ *ទិវាមច្ឆជាតិ* ដោយតម្រូវឱ្យប្រារព្ធធ្វើនៅថ្ងៃទី ០១ ខែ កក្កដា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬ ព្រះរាជតំណាង (មាត្រា ១៧ ច្បាប់ស្តីពី ជលផល ២០០៦) ។

## ៣. តំបន់គ្រប់គ្រងជលផល

តំបន់គ្រប់គ្រងជលផល គឺជាកន្លែងនេសាទគ្រប់ប្រភេទ កន្លែងអភិរក្សជលផល តំបន់ឆ្នេរសមុទ្រ តំបន់ផ្កាថ្ម ទំនាបលិចទឹកក្នុងរដូវទឹកជំនន់ឡើង នាទីព្រៃលិចទឹក ព្រៃកោងកាង ដូចមានចែងក្នុងមាត្រា ១០ និងមាត្រា ១១ នៃច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦។

ការបង្កើត ការរំសាយ តំបន់គ្រប់គ្រងជលផល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការផ្តល់កម្មសិទ្ធិក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបាន លុះត្រាមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ។ ចំណែកនីតិវិធីនៃការបង្កើត រំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ៤ .អំពីដែននេសាទ និងការគ្រប់គ្រងអាជីវកម្មនេសាទ

### ៤.១. និយមន័យដែននេសាទ:

ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ការប្រើប្រាស់ដែននេសាទក្រៅពីគោលបំណងវិស័យជលផល ត្រូវសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ៩ ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦) ។ ដែននេសាទរួមមាន: ដែនដីលិចទឹកជាអចិន្ត្រៃយ៍ជាអាទិ៍: សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ ឬដែនដីដែលទទួលរបបទឹកទន្លេមេគង្គជាអាទិ៍: ត្រពាំង រណ្តៅ វាលភក់ ល្បាប់ វាលទំនាបលិចទឹកក្នុងរដូវទឹកជំនន់ឡើង និងនាទីព្រៃលិចទឹក ព្រមទាំងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រជាអាទិ៍: នាទីព្រៃកោងកាង ដែលមានតួនាទីសំខាន់

បម្រើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល ( មាត្រា ៩ ច្បាប់ស្តីពីជលផល ២០០៦) ។ ដែននេសាទរួមមាន *ដែននេសាទទឹកសាប* និង *ដែននេសាទសមុទ្រ* ។

**ក. ដែននេសាទទឹកសាបៈ**

ផ្អែកលើមាត្រាទី ១០ នៃច្បាប់ស្តីពីជលផលចែងថាៈ ដែននេសាទទឹកសាប គឺជាផ្ទៃទឹកដែលលាតសន្ធឹងចាប់ពីដែននេសាទសមុទ្ររហូតដល់ព្រំប្រទល់ដីគោកនៃព្រះរាជាណាចក្រកម្ពុជា ។

ដែននេសាទទឹកសាបរួមមានៈ

- ឡូត៍នេសាទទុកសម្រាប់សម្បទានដល់ការវិនិយោគ ឬ ជួលឱ្យធ្វើអាជីវកម្មនេសាទ
- កន្លែងអភិរក្សជលផលដែលជាជម្រករក្សាពូជវារីសត្វ និងវារីរុក្ខជាតិ
- នាទីព្រៃលិចទឹករួមមាន តំបន់ព្រៃលិចទឹកដែលជាជម្រកចាំបាច់របស់វារីសត្វ ក្នុងការស្វែងរកចំណី ឬ កន្លែងពងកូន និង*តំបន់លិចទឹកដែលត្រូវការពារ* ។

***<u>កំណត់សម្គាល់:</u>*** តំបន់លិចទឹកដែលត្រូវការពាររួមមានៈ ដីលិចទឹកដែលស្ថិតនៅក្នុងនាទីឡូត៍នេសាទ នាទីព្រៃលិចទឹក និងព្រៃកោងកាង ដែលត្រូវការពារសម្រាប់ដាំ ឬ រក្សាទុកឱ្យដុះព្រៃឡើងវិញ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល ( មាត្រា ២៧ ច្បាប់ស្តីពីជលផល ២០០៦) ។

- កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ
- កន្លែងនេសាទបម្រុង ជាកន្លែងនេសាទទាំងឡាយដែលពុំបានធ្វើការចាត់ថ្នាក់
- កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម
- ទំនាបលិចទឹកក្នុងរដូវដំឡើង

**ខ. ដែននេសាទសមុទ្រ**

ផ្អែកលើមាត្រាទី ១១ នៃច្បាប់ស្តីពីជលផលចែងថាៈ ដែននេសាទសមុទ្រ គឺជាផ្ទៃទឹកសមុទ្រ ឬ ទឹកភ្លាវដែលលាត សន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃតំបន់ឆ្នេរ រហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា ។

ដែននេសាទសមុទ្ររួមមានៈ

- កន្លែងនេសាទតាមឆ្នេរ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត រហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ (២០) ម៉ែត្រ ។
- កន្លែងនេសាទសមុទ្រខាងក្រៅ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ (២០) ម៉ែត្ររហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា ។

- កន្លែងអភិរក្សជលផល តំបន់ឆ្នេរសមុទ្រ និងតំបន់ផ្កាថ្ម ដែលជាជម្រករក្សាពូជវារីសត្វ និងវារីរុក្ខជាតិ ។

- នាទីព្រៃកោងកាង រួមមានៈ ព្រៃកោងកាង និងព្រៃទាំងអស់ដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណី ឬ កន្លែងពងកូន និងតំបន់លិចទឹកដែលត្រូវការពារ ។

### ៤.២. ការគ្រប់គ្រងអាជីវកម្មនេសាទ

ការធ្វើអាជីវកម្មនេសាទទឹកសាប និងការធ្វើអាជីវកម្មនេសាទសមុទ្រត្រូវមានៈ លិខិតអនុញ្ញាតបង់ថ្លៃឈ្នួលនេសាទ និងត្រូវគោរពបទបញ្ញាផ្សេងទៀតរបស់រដ្ឋបាលជលផល ។

ការប្រគល់ឡូត៍នេសាទឱ្យធ្វើអាជីវកម្មនេសាទ អាចប្រព្រឹត្តទៅបានតាមការវិនិយោគ តាមការដេញថ្លៃជាសាធារណៈ ឬ ជួលតាមការព្រមព្រៀងក្នុងករណីឡូត៍នេសាទគ្មានអ្នកដេញថ្លៃ ។

## ៥. ឧបករណ៍នេសាទ

ការធ្វើអាជីវកម្មនេសាទទឹកសាប និងការធ្វើអាជីវកម្មនេសាទសមុទ្រ ត្រូវបានកំណត់តាមប្រភេទឧបករណ៍នេសាទគឺៈ

- ឧបករណ៍នេសាទគ្រួសារ ( មាត្រា ៣១)

ឧបករណ៍នេសាទគ្រួសារ គឺជាឧបករណ៍នេសាទដែលប្រើប្រាស់សម្រាប់នេសាទជាលក្ខណៈគ្រួសារ ហើយត្រូវបានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលាក្នុងកន្លែងនេសាទគ្រួសារ ក្នុងឡូត៍ដែននេសាទទឹកសាបក្នុងរដូវបិទនេសាទ ឬ នៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទគ្រួសារ។

- ឧបករណ៍នេសាទសិប្បកម្ម ( មាត្រា ៣១)

ឧបករណ៍នេសាទសិប្បកម្ម គឺជាឧបករណ៍នេសាទដែលប្រើប្រាស់សម្រាប់នេសាទជាលក្ខណៈសិប្បកម្ម និងមានលក្ខណៈទោល។ លក្ខណៈសម្គាល់របស់វា យោលទៅតាមទ្រង់ទ្រាយ ទំហំ ប្រភេទ និងចំនួននៃឧបករណ៍នោះ ហើយត្រូវបានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានៅក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬ ក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទសិប្បកម្ម ។

- ឧបករណ៍នេសាទឧស្សាហកម្ម ( មាត្រា ៣១)

ឧបករណ៍នេសាទឧស្សាហកម្ម គឺជាឧបករណ៍នេសាទដែលប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈឧស្សាហកម្ម ហើយឧបករណ៍នេះត្រូវបានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាចប្រព្រឹត្តទៅបានតែនៅក្នុងឡូត៍នេសាទនៃដែននេសាទទឹកសាប ឬ ក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទឧស្សាហកម្ម ។

## ៦. ការធ្វើអាជីវកម្មនេសាទ

ការធ្វើអាជីវកម្មនេសាទរួមមាន ការធ្វើអាជីវកម្មនេសាទទឹកសាប និងការធ្វើអាជីវកម្មនេសាទសមុទ្រ ។

- **ការធ្វើអាជីវកម្មនេសាទទឹកសាប**

ការធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាត សៀវភៅបន្ទុក និងក្នុងរដូវបើកនេសាទ ។

ចំពោះរដូវបិទនេសាទសម្រាប់ការនេសាទសិប្បកម្មត្រូវកំណត់ដូចខាងក្រោម:

☞ ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ កញ្ញា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ ។

☞ ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ដល់ថ្ងៃទី ៣១ ខែ តុលា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ ។

រដ្ឋបាលជលផល ជាអ្នកទទួលបន្ទុកស្រាវជ្រាវ និងតាមដានរដូវត្រីពងកូន រដូវនេសាទសម្រាប់តំបន់ ឬ ប្រភេទធនធានជលផលផ្សេងទៀត។ រដូវត្រីពងកូន រដូវនេសាទសម្រាប់តំបន់ ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ១៦ ច្បាប់ស្តីពីជលផល ២០០៦) ។

- **ការធ្វើអាជីវកម្មនេសាទសមុទ្រ**

ការធ្វើអាជីវកម្មនេសាទសមុទ្រគ្រប់ប្រភេទក្នុងដែននេសាទសមុទ្រ អាចប្រព្រឹត្តទៅបានលុះត្រាមានលិខិតអនុញ្ញាត និងលក្ខខណ្ឌផ្សេងៗមួយចំនួនទៀតដែលបានចែងក្នុងសៀវភៅបន្ទុក លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ ( មាត្រា ៤៥ ) ។

អាជីវករនេសាទសមុទ្រត្រូវផ្ទេរផលនេសាទនៅកំពង់ផែនេសាទតាមការកំណត់របស់រដ្ឋបាលជលផល ។

នាវានេសាទបរទេសដែលមានលិខិតអនុញ្ញាតរួចហើយ តម្រូវឱ្យផ្តល់ព័ត៌មានមករដ្ឋបាលជលផលជាមុន មុននឹងចូលមកសំចតក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

រដ្ឋបាលជលផលមានសិទ្ធិផ្អាកសកម្មភាពបន្ទាន់ជាបណ្តោះអាសន្ន និងលើកសំណើពិនិត្យឡើងវិញ លើកិច្ចព្រមព្រៀងនេសាទ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើការស្រាវជ្រាវវិទ្យាសាស្ត្រជាក់លាក់ករណីរកឃើញថា ការនេសាទនោះបានធ្វើឱ្យប៉ះពាល់ និងគំរាមកំហែងធ្ងន់ធ្ងរដល់ធនធានជលផល ( មាត្រា ៤៨ ច្បាប់ដដែល)

**ការហាមឃាត់:**

⊙ ការធ្វើនេសាទដោយអូនអូសគូប្បផ្សំកំលាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរ លើកលែងតែការនេសាទនោះធ្វើឡើងដើម្បីសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រតាមសំណើរបស់រដ្ឋបាលជលផល បន្ទាប់ពីបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ៤៩ ច្បាប់ស្តីពីជលផល) ។

◉ ការរៀបចំទុកដាក់ឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទ ចំពោះនាវានេសាទទាំងឡាយណាដែលគ្មានលិខិតអនុញ្ញាត ។

◉ នាវានេសាទដែលបំពាក់ឧបករណ៍នេសាទអួនអូស ឬ ឈ្នាងអូសត្រំក្រឡាហួលដែលអូស ឬ រុញដោយកំលាំងម៉ាស៊ីនហើយចូលឆ្លងកាត់កន្លែងនេសាទតាមឆ្នេរ ( មាត្រា ៥០ ច្បាប់ស្តីពីជលផល) ។

◉ ការធ្វើនេសាទ ឬ ការធ្វើអាជីវកម្មផ្សេងៗដែលប៉ះពាល់ ឬ វិនាសដល់ការលូតលាស់ស្មៅសមុទ្រ ឬ ផ្កាថ្ម ( មាត្រា ៥២ ច្បាប់ស្តីពីជលផល)

◉ ការប្រមូលផល ការទិញ ការលក់ ការដឹកជញ្ជូន និងការធ្វើសន្និធិផ្កាថ្ម ។

◉ ការចូលសំចត ឬ បោះយុថ្កាក្នុងតំបន់ផ្កាថ្ម ។

◉ ការបំផ្លាញស្មៅសមុទ្រ ឬ ផ្កាថ្មដោយសកម្មភាពផ្សេងទៀត ( មាត្រា ៥២ ច្បាប់ស្តីពីជលផល) ។

### ៩.៣. ការគ្រប់គ្រងនាទីព្រៃលិចទឹក និងព្រៃកោងកាង

នាទីព្រៃលិចទឹក និងព្រៃកោងកាង គឺសំដៅផ្ទៃដីលិចទឹកដោយរបបទឹកទន្លេមេគង្គ ឬ ដីលិចទឹកដោយរបបទឹកជោរនាច នៃសមុទ្រដែលគ្របដណ្តប់ដោយព្រៃលិចទឹក និងព្រៃកោងកាង ព្រមទាំងតំបន់លិចទឹកដែលត្រូវការពារផងដែរ ។

ហាមឃាត់ ការបង្កភ្លើងឆេះព្រៃក្នុងនាទីព្រៃលិចទឹក និងព្រៃកោងកាង ។ ប៉ុន្តែលើកលែង ករណីរដ្ឋបាលជលផលប្រើប្រាស់ភ្លើងប្រយោជន៍វប្បកម្ម ឬ ធ្វើអនាម័យព្រៃ។ គណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាងត្រូវបានបង្កើតឡើងដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ២៦ ច្បាប់ស្តីពីជលផល) ។

# ជំពូក ២

# សហគមន៍នេសាទ

## ១. និយមន័យ

សហគមន៍នេសាទ គឺជារូបវន្តបុគ្គលមួយក្រុម ឬ ជាក្រុមរូបវន្តបុគ្គលដែលរៀបចំឡើងដោយអ្នកមានសញ្ជាតិខ្មែរ ហើយដែលរស់នៅក្នុង ឬ ទីជិតខាងនៃដែននេសាទ ។ ក្នុងនោះ មានកន្លែងដែលរដ្ឋបានប្រគល់ឱ្យរួមមានៈ ដែននេសាទដែលបានលុបចេញ ឬ កាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទបំរុង នាទីព្រៃលិចទឹក ព្រៃកោងកាង និងដែននេសាទសមុទ្រ ដោយរួមគ្នាបង្កើតឡើងដោយស្ម័គ្រចិត្តដើម្បី គិតគូរពីផលប្រយោជន៍រួម និងចូលរួមគ្រប់គ្រងប្រើប្រាស់ ការពារធនធានជលផលដោយផ្ទាល់ប្រកបដោយចីរភាព និង ដើម្បីកាត់បន្ថយភាពក្រីក្រ ក្រោមការជួយជ្រោមជ្រែងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ/សង្កាត់ ។

## ២. វិធាននៃការការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ

### ២.១. លក្ខខណ្ឌនៃការបង្កើតសហគមន៍នេសាទ

សហគមន៍នេសាទដើម្បីទទួលស្គាល់ជាផ្លូវការ ឬ ជានីតិបុគ្គល ចាំបាច់ត្រូវតែចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការចុះបញ្ជី តម្រូវឱ្យសហគមន៍នេសាទភ្ជាប់មកជាមួយនូវៈ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការកន្លែងនេសាទសហគមន៍ ។

### ក. អំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

***តើអ្វីជាលក្ខន្តិកៈ ?***

លក្ខន្តិកៈ គឺជាច្បាប់គ្រឹះ ឬ ច្បាប់ផ្ទៃក្នុងរបស់សហគមន៍នេសាទ ដែលត្រូវបានរៀបចំឡើង និងធ្វើការអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ។ ប៉ុន្តែ លក្ខន្តិកៈនេះមិនអាចចែងផ្ទុយច្បាប់រដ្ឋបានឡើយ ។

លក្ខន្តិកៈសហគមន៍នេសាទអាចធ្វើការកែសម្រួលបានគ្រប់ពេលវេលា ឱ្យតែផ្តល់ផលប្រយោជន៍ចំពោះសហគមន៍នេសាទ។ គ្រាន់តែការសម្រេចនោះធ្វើឡើងដោយមហាសន្និបាតសហគមន៍នេសាទ។ មាត្រា ៨ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ នេសាទបានចែងអំពីចំណុចសំខាន់ៗ នៃលក្ខន្តិកៈសហគមន៍នេសាទត្រូវមានៈ

-នាមករណ៍

-ទីស្នាក់ការ និងអាសយដ្ឋាន

-កម្មវត្ថុ

-លក្ខខណ្ឌនៃការសុំចូលជាសមាជិក

-កាតព្វកិច្ច និងសិទ្ធិរបស់សមាជិក

-លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញសមាជិក

-របៀបរបបនៃការកាន់បញ្ជី និងឯកសារនានា

-សមាសភាពនៃគណៈកម្មការសហគមន៍នេសាទ

-លក្ខខណ្ឌនៃការកោះប្រជុំមហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ

-លក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍កម្រៃពីការធ្វើសេដ្ឋកិច្ចសមូហភាព (បើសិនជាមាន)

-លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ

-នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

*តើបទបញ្ជាផ្ទៃក្នុងជាអ្វី ?*

បទបញ្ជាផ្ទៃក្នុង គឺជាច្បាប់ ឬ ជាវិធានដែលបំពេញបន្ថែមឱ្យលក្ខន្តិកៈនៃសហគមន៍នេសាទ ដែលវិធាននេះសម្រាប់គ្រប់គ្រងសកម្មភាពរបស់សហគមន៍នេសាទ និងជាវិធានសម្រាប់ដាក់ទណ្ឌកម្មទៅដល់អ្នកពាក់ព័ន្ធដែលបានធ្វើឱ្យប៉ះពាល់ ឬ ធ្វើឱ្យខូចផលប្រយោជន៍សហគមន៍នេសាទ ជាពិសេសសមាជិកនៃសហគមន៍នេសាទ។ នីតិវិធីនៃការកែប្រែ ឬ វិសោធនកម្ម គឺដូចគ្នានឹងការកែប្រែ ឬ វិសោធនកម្មលក្ខន្តិកៈដែរ ។ បទបញ្ជាផ្ទៃក្នុង ពុំអាចចែងផ្ទុយពីច្បាប់រដ្ឋបានទេ ។ *ឧទាហរណ៍*: ចែងទោសពន្ធនាគារជាដើម ។ល។ ព្រោះថា ទោសពន្ធនាគារជារឿងព្រហ្មទណ្ឌដែលជារឿងរួម ជាភារកិច្ចរបស់រដ្ឋ ឬ ជាការដាក់ទណ្ឌកម្មចំពោះអ្នកដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ ។ ដូចនេះមានតែរដ្ឋទេ ទើបមានសិទ្ធិដាក់ទណ្ឌកម្មនេះដល់អ្នកពាក់ព័ន្ធទាំងនោះ ។

## ខ. កិច្ចព្រមព្រៀង និងផែនទីសហគមន៍នេសាទ:

កិច្ចព្រមព្រៀងសហគមន៍នេសាទ គឺជាកិច្ចសន្យា ឬ ជាច្បាប់របស់ភាគីសហគមន៍នេសាទ ដែលបានចុះកិច្ចសន្យាជាមួយភាគីរដ្ឋ ដើម្បីទទួលយកដែននេសាទមកគ្រប់គ្រង ដោយធានានូវនិរន្តរភាពនៃធនធានជលផល សំដៅចូលរួមគ្រប់គ្រងធនធានធម្មជាតិដោយផ្ទាល់ និងកាត់បន្ថយភាពក្រីក្រ។ គណៈកម្មាការសហគមន៍នេសាទជាអ្នករៀបចំធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងសហគមន៍នេសាទ ហើយសេចក្តីព្រាងនេះ តម្រូវឱ្យប្រកាសបិទផ្សាយនៅកន្លែងសាធារណៈយ៉ាងតិច ៣០ ថ្ងៃ បន្ទាប់ពីមានការឯកភាពគ្នារវាង គណៈកម្មាការសហគមន៍នេសាទរួច។ ការបិទផ្សាយធ្វើនៅ សាលាឃុំ/សង្កាត់ ឬ សាលាស្រុក/ខណ្ឌ ឬ សាលាខេត្ត/ក្រុង មុននឹងដាក់ជូនប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាលពិនិត្យ ។ ផ្អែកតាមមាត្រា ៦១ នៃច្បាប់ស្តីពីជលផល

ឆ្នាំ ២០០៦ ចែងថា: នាយខណ្ឌរដ្ឋបាលជលផលជាអ្នកសម្រេចចុះ ឬ លុបកិច្ចព្រមព្រៀងសហគមន៍នេសាទ។ កិច្ចព្រមព្រៀងមានសុពលភាពមិនលើស ៣ ឆ្នាំឡើយ។ ប៉ុន្តែកិច្ចព្រមព្រៀងនេះអាចពន្យាពេលបាន ដោយសហគមន៍នេសាទត្រូវជូនដំណឹងមករដ្ឋបាលជលផលថ្នាក់កណ្តាល ៦ ខែ មុនផុតកំណត់នៃកិច្ចព្រមព្រៀង។ ចំណែករដ្ឋបាលជលផលក៏ត្រូវផ្តល់ដំណឹងទៅសហគមន៍នេសាទដែរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលពាក្យសុំពន្យាពេលនេះ បើមិនដូច្នោះទេ ច្បាប់សន្មត់ថា កិច្ចព្រមព្រៀងនឹងបន្តដោយស្វ័យប្រវត្តិ។ ប៉ុន្តែ កិច្ចព្រមព្រៀងសហគមន៍នេសាទ ក៏អាចបញ្ឈប់មុនការកំណត់បានដែរ ក្នុងករណី:

១.ឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ

២.ការព្រមព្រៀងគ្នា ក្នុងគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាព ២/៣ ពីសមាជិកសហគមន៍នេសាទ

៣.ការមិនអនុវត្ត ឬ អនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងបទប្បញ្ញត្តិនានាដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ចីរភាពនៃធនធានជលផល ។

៤.ការយល់ឃើញរបស់រដ្ឋាភិបាលនូវគោលបំណងផ្សេងណាមួយទៀតដែលផ្តល់ផលប្រយោជន៍សាធារណៈ និងសង្គមច្រើនជាង ( មាត្រា ២៧ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងមាត្រា ៦១ ច្បាប់ស្តីពីជលផលឆ្នាំ ២០០៦ ) ។

*កំណត់សម្គាល់:*

-ចំពោះការរំសាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដោយរដ្ឋាភិបាលគ្មានមូលហេតុច្បាស់លាស់ សហគមន៍នេសាទមានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចតាមឋានានុក្រម ឬ ស្ថាប័នតុលាការអំពីការរំសាយ ឬ លុបកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នេះ ។

-ចំពោះការរំសាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដោយរដ្ឋាភិបាល ឬ ដោយសហគមន៍នេសាទខ្លួនឯង ដែននេសាទត្រូវក្លាយមកជាទ្រព្យសម្បត្តិរដ្ឋវិញដោយស្វ័យប្រវត្តិ ។ ឯទ្រព្យសម្បត្តិផ្សេងទៀត ត្រូវសងបំណុលជាអាទិភាព និងទ្រព្យសម្បត្តិដែលនៅសល់ត្រូវសម្រេចដោយមហាសន្និបាតសហគមន៍នេសាទ ។

ចំពោះផែនទី គណៈកម្មការសហគមន៍នេសាទជាអ្នករៀបចំព្រាង ដោយមានការជួយជ្រោមជ្រែងពីរដ្ឋបាលជលផលមានសមត្ថកិច្ច ។ ផែនទីត្រូវមានមាត្រដ្ឋាន ១/៥០.០០០ ដោយបញ្ជាក់ពីតំបន់ស្នើសុំ និងនិយាមការច្បាស់លាស់

### ឥ. អំពីផែនការគ្រប់គ្រងសហគមន៍នេសាទ

ផែនការគ្រប់គ្រងសហគមន៍នេសាទ ត្រូវធ្វើបន្ទាប់ពីមានកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។ ផែនការនេះ ក៏ត្រូវបានការជួយជ្រោមជ្រែង និងជួយរៀបចំពីសំណាក់រដ្ឋបាលជលផលផងដែរ។ ផែនការនេះ ចាំបាច់ត្រូវតែមានការយល់ព្រមអំពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ( មាត្រា ៦២ ច្បាប់ស្តីពីជលផលឆ្នាំ ២០០៦) ។

ផែនការគ្រប់គ្រងសហគមន៍នេសាទមានរយៈពេល ៣ ឆ្នាំ ។ ខណ្ឌរដ្ឋបាលជលផលជាអ្នកត្រួតពិនិត្យឡើងវិញជារៀង

រាល់ឆ្នាំ ឬមុនពេលកំណត់។ ករណីចាំបាច់ ត្រូវរាយការណ៍ជូនប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។ ចំពោះ ការវាយតម្លៃការត្រួតពិនិត្យផែនការ ត្រូវមានការចូលរួមពីគណៈកម្មការសហគមន៍នេសាទ។ ការកែតម្រូវផែនការអាចធ្វើឡើងបានករណីមិនស្របតាមបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យជលផល។ តាមមាត្រា ៦២ នៃច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ ចែងថា: *ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាន និងមានការយល់ព្រមពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ហើយនិងត្រូវពិនិត្យឡើងវិញជារៀងរាល់ បី (៣)ឆ្នាំ ម្តង ឬ មុនពេលកំណត់ក្នុងករណីចាំបាច់។*

## ២.២. លក្ខខណ្ឌសុំចូលជាសមាជិក សិទ្ធិ និងតួនាទីភារកិច្ចរបស់សមាជិកសហគមន៍នេសាទ

### ក. លក្ខខណ្ឌសុំចូលជាសមាជិកសហគមន៍នេសាទ

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងសុំចូលជាសមាជិកសហគមន៍នេសាទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:

- មានទីលំនៅក្នុងបណ្តុំភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង។

ប៉ុន្តែបុគ្គលម្នាក់អាចចូលជាសមាជិកសហគមន៍នេសាទបានតែមួយគត់នៃសហគមន៍នេសាទដែលខ្លួនរស់នៅ (មាត្រា៩ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ)។

### ខ. សិទ្ធិ និងតួនាទីភារកិច្ចសមាជិកសហគមន៍នេសាទ:

សមាជិកសហគមន៍នេសាទ បន្ទាប់ពីបានចូលជាសមាជិកពេញសិទ្ធិតាមលក្ខខណ្ឌនៃលក្ខន្តិកៈរួចសមាជិករូបនោះ នឹងទទួលបានសិទ្ធិដូចតទៅ:

- ចូលរួមប្រជុំ និងបោះឆ្នោតស្មើភាពគ្នា ។ ប៉ុន្តែករណីមានសមាជិកសហគមន៍នេសាទណាម្នាក់បានរារាំងឬធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍ ឬ សមាជិកសហគមន៍នេសាទដទៃទៀតសមាជិករូបនោះអាចត្រូវព្យួរ ឬ បណ្តេញចេញពីសហគមន៍ ក្រោយពីបានការពារខ្លួនចំពោះមុខគណៈកម្មាការសហគមន៍នេសាទ ។
- បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតក្នុងរចនាសម្ព័ន្ធគណៈកម្មាការសហគមន៍នេសាទ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មាការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសមញ្ញដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ។ ប៉ុន្តែ ការស្នើសុំនេះ តម្រូវឱ្យមានសមាជិកយ៉ាងតិច១/៣នៃសមាជិកទាំងអស់របស់សហគមន៍នេសាទជាអ្នកស្នើទើបចាត់ទុកបានការ
- ធ្វើសំណូមពរឱ្យដាក់ចូលរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយណាដែលមានប្រយោជន៍សម្រាប់សហគមន៍នេសាទ

- ធ្វើនេសាទជាលក្ខណៈគ្រួសារ តាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យជលផល និងលក្ខន្តិកៈសហគមន៍នេសាទ

- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ

- ប្តឹងតវ៉ា ឬ ផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចជលផល ឬក្រុមប្រឹក្សាឃុំ សង្កាត់ ឬ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ។ ដោយឡែក ចំពោះសមាជិកថ្មីដែលទើបសុំចូលជាសមាជិកសហគមន៍ ត្រូវបញ្ជាក់អំពីការសុខចិត្តគោរពច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ព្រមទាំងសេចក្តីសម្រេចនានារបស់មហាសន្និបាតសហគមន៍នេសាទ ។ សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរៀងៗខ្លួន និងរួមគ្នាដែរ ចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ ដោយឡែកអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ គឺមានសិទ្ធិចេញចូល និងប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ។ ប៉ុន្តែ ត្រូវតែគោរពតាមច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ( មាត្រា ១៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ) ។

## គ. សិទ្ធិ និងតួនាទីភារកិច្ចរបស់សហគមន៍នេសាទ

### គ.១ សិទ្ធិសហគមន៍នេសាទរួមមានៈ

- ចាត់ចែងការធ្វើនេសាទរបស់សមាជិកទាំងអស់ឱ្យបានសមស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។

- សហការជាមួយសមត្ថកិច្ចជលផលដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ ។ ក្នុងករណីបន្ទាន់ និងចាំបាច់សហគមន៍នេសាទ អាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាង ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស រួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផលដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

- ធ្វើទំនាក់ទំនងជាមួយសហគមន៍នេសាទនានា ឬ រូបវន្តបុគ្គល ឬ នីតិបុគ្គលដើម្បីផលប្រយោជន៍សហគមន៍ ។

- ធ្វើនេសាទ ធ្វើវារីវប្បកម្ម ប្រមូលផល លក់ ប្រើប្រាស់ និងគ្រប់គ្រងរាល់ធនធានជលផលស្របតាមកិច្ចព្រមព្រៀង និងផែនការសហគមន៍នេសាទ ។

<u>លក្ខខណ្ឌហាមឃាត់ៈ</u>

មាត្រា ១២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ក៏បានហាមឃាត់នូវសិទ្ធិមួយចំនួនរបស់សហគមន៍នេសាទផងដែរ ។ ការហាមឃាត់នោះរួមមានៈ

◉ ការលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ខ្ចី បញ្ចាំ ឬ ផ្ទេរកន្លែងនេសាទសហគមន៍ ទោះបីតាមរូបភាពណាក៏ដោយ ។ ចំណុចនេះ មាត្រា ៦២ នៃច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦ ក៏បានចែងការហាមឃាត់ផងដែរ ។

◉ ធ្វើទំនប់ ឬ ធ្វើនេសាទដែលបណ្តាលឱ្យរាំងស្ទះមុខព្រែក អូរ ប្រឡាយ ឬ ចរាចរត្រី ។ ប៉ុន្តែអាចលើកលែងករណី

មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងតាមសំណើរបស់ប្រធានរដ្ឋបាលជលផលថ្នាក់កណ្ដាលរួច ។

⊙ បែងចែកធ្វើជាកម្មសិទ្ធិឯកជននូវដីព្រៃលិចទឹក និងព្រៃកោងកាង ដីលិចទឹក ព្រមទាំងកន្លែងនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្ដល់ឱ្យ ។

⊙ ចុះកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធក្នុងកន្លែងនេសាទសហគមន៍ជាមួយរូបវន្តបុគ្គល ឬ នីតិបុគ្គលនានាទោះបីស្រាវជ្រាវវិទ្យាសាស្ត្រក៏ដោយ ។

### គ.២. តួនាទី ភារកិច្ចរបស់សហគមន៍នេសាទ

តួនាទី ភារកិច្ចសហគមន៍នេសាទរួមមាន:

- ចូលរួមគ្រប់គ្រង អភិរក្សធនធានជលផលស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្របច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។
- គោរពតាមការណែនាំរបស់រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ចូលរួមបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ថែរក្សាការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាង ស្មារព្រែក បឹង រឹងរាក់ ដើម្បីកែលំអប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានឡើងវិញ ។
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍នេសាទមានសិទ្ធិស្មើគ្នា លើការប្រើប្រាស់ធនធានជលផលដោយចិរភាពដូចមានចែងក្នុងលក្ខន្តិកៈ ។
- អនុវត្តលក្ខន្តិកៈសហគមន៍នេសាទ និងធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។
- ចុះកិច្ចព្រមព្រៀងជាមួយនាយខណ្ឌរដ្ឋបាលជលផល ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយចិរភាព (មាត្រា ៦១ ច្បាប់ស្ដីពីជលផល ឆ្នាំ ២០០៦) ។
- រក្សាទុកឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។
- ចំពោះ សហគមន៍ដែលមានដែននេសាទជាប់គ្នាអាចចូលរួមជាមួយគ្នាដោយបង្កើតជាសហព័ន្ធសហគមន៍នេសាទបាន ( មាត្រា ៣ នៃព្រះរាជក្រឹត្យស្ដីពីការបង្កើតសហគមន៍នេសាទ ) ។

### ឃ. ការជ្រើសរើសប្រធាន និងគណៈកម្មការសហគមន៍នេសាទ

ការគ្រប់គ្រងសហគមន៍នេសាទ ចាំបាច់ត្រូវមានប្រធាន និងគណៈកម្មការសម្រាប់ដឹកនាំ និងគ្រប់គ្រង ។ មាត្រា ១៥ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទបញ្ញត្តិថា: " *សហគមន៍នេសាទនីមួយៗ ត្រូវដឹកនាំដោយគណៈកម្មការមួយហៅថា "**គណៈកម្មការសហគមន៍នេសាទ**" ។ គណៈកម្មការសហគមន៍នេសាទនេះ ត្រូវជ្រើសរើសតាមការបោះឆ្នោតរបស់មហាសន្និបាតដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រភាគច្រើនដាច់ខាតពីសមាជិកសហគមន៍នេសាទ*

*និងបានទទួលរួម*" ។

ម.១. ការជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

មាត្រា ១៨ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ បញ្ញត្តិថា: "*ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិនិងបំពេញឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសជាគណៈកម្មការសហគមន៍នេសាទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:*

*ក.ជាសមាជិកនៃសហគមន៍នេសាទសាមី*

*ខ.មានសញ្ជាតិខ្មែរពីកំណើត* ។"

សមាជិកគណៈកម្មការសហគមន៍នេសាទត្រូវមានចំនួនពី ៥ នាក់ ទៅ ១១ នាក់ ទៅតាមការជាក់ស្តែង និងតាមការសម្រេចរបស់មហាសន្និបាត ។ ចំពោះស្ត្រីភេទ ត្រូវបានលើកទឹកចិត្តឱ្យឈរឈ្មោះជាបេក្ខជនគណៈកម្មការ។ គណៈកម្មការសហគមន៍នេសាទមានអណត្តិ ៥ ឆ្នាំ និងផុតកំណត់នៅពេលគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែង ( មាត្រា ១៧ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ) ។

ម.២. ការជ្រើសរើសប្រធានគណៈកម្មការសហគមន៍នេសាទ:

មាត្រា ១៦ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ បញ្ញត្តិថា: "*បេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតបន្ទាប់ គឺជាអនុប្រធានគណៈកម្មការសហគមន៍នេសាទ ។*

*សមត្ថកិច្ចជលផល សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ឬ ក្រុមប្រឹក្សាឃុំ / សង្កាត់ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ ឬ សម្របសម្រួលក្នុងការបោះឆ្នោត ។ លទ្ធផលនៃការបោះឆ្នោតត្រូវទទួលស្គាល់ជាផ្លូវការ ទោះបីអវត្តមាននៃសមត្ថកិច្ចជលផល សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដោយ* ។"

## ៣. ស្ថាប័នគ្រប់គ្រង និងប្រភពថវិការបស់សហគមន៍នេសាទ

### ៣.១. ស្ថាប័នគ្រប់គ្រង

**ក. តួនាទី ភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:**

- ធ្វើជាអាណាព្យាបាលរបស់សហគមន៍នេសាទ
- ចេញប្រកាសទទួលស្គាល់ បដិសេធ ឬ រំសាយសហគមន៍នេសាទ
- ចេញប្រកាសស្តីពីគោលការណ៍ណែនាំដល់សហគមន៍នេសាទ នូវគំរូលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមរយៈដំណើរការពិគ្រោះយោបល់
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត លើការអនុវត្ត និងការអភិវឌ្ឍក្នុងការគ្រប់គ្រង

សហគមន៍នេសាទ

- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់សហគមន៍

- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ

**ខ. តួនាទី ភារកិច្ចរបស់រដ្ឋបាលជលផល:**

មាត្រា ២៣ នៃអនុក្រឹត្យដដែលបានផ្តល់ឱ្យនូវ តួនាទី ភារកិច្ចរដ្ឋបាលជលផលមានចំពោះសហគមន៍ដូចខាងក្រោម:

- ពិនិត្យផ្តល់យោបល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្រេចបង្កើតសហគមន៍នេសាទ

- ពិនិត្យ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយសហគមន៍នេសាទ

- ធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបញ្ឈប់កិច្ចព្រមព្រៀង ក្នុងករណីពិនិត្យឃើញថា សហគមន៍នេសាទមិនគោរពតាមខ្លឹមសារនៃកិច្ចព្រមព្រៀង

- ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

- ពិនិត្យ និងដោះស្រាយរាល់សំណើរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយចិរភាព

- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍

- ដោះស្រាយទំនាស់លើវិស័យជលផលក្នុងកន្លែងនេសាទសហគមន៍

- សម្របសម្រួលក្នុងការរៀបចំសហគមន៍នេសាទ កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ លក្ខន្តិកៈសហគមន៍នេសាទផែនការគ្រប់គ្រងសហគមន៍នេសាទ និងការធ្វើសកម្មភាពគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទ

- ផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល និងឯកសារដែលទាក់ទងនឹងសហគមន៍នេសាទ

- អប់រំបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពបច្ចេកទេសជំនាញសម្រាប់ការគ្រប់គ្រងដល់សហគមន៍នេសាទ

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់សហគមន៍នេសាទ

- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ

## ៣.២ ប្រភពថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ:

ការអនុវត្តជាក់ស្តែង យើងពិនិត្យឃើញថា រាល់សកម្មភាព និងដំណើរការរបស់សហគមន៍នេសាទគឺដូចគ្នានឹងសកម្មភាពរបស់ក្រុមហ៊ុនដែរ គ្រាន់តែសហគមន៍នេសាទធ្វើកិច្ចការមិនស្វែងរកប្រាក់ចំណេញ ។ ព្រោះថា សហគមន៍នេសាទដែលបង្កើតឡើងមានគោលបំណងតែម្យ៉ាង គឺការពារផលប្រយោជន៍រួម ។ ប៉ុន្តែ ចំណុចរួមរបស់ក្រុមហ៊ុន និងសហគមន៍នេសាទអាចដំណើរការទៅបានលុះត្រាតែមានថវិកាសម្រាប់ទ្រទ្រង់ ។ ប៉ុន្តែ ថវិកាទាំងនោះ គឺបានមកពីប្រភពផ្សេងៗ គ្នា ។ ដោយឡែក មាត្រា ៣០ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទបានកំណត់ថា: ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី:

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា
- ចំណូលស្របច្បាប់ផ្សេងទៀត

# ជំពូក ៣
# ការគ្រប់គ្រងវារីវប្បកម្ម ការដឹកជញ្ជូន
# និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល

## ១. ការគ្រប់គ្រងវារីវប្បកម្ម

ការធ្វើវារីវប្បកម្មរួមមាន ការធ្វើវារីវប្បកម្មទឹកសាប និងការធ្វើវារីវប្បកម្មសមុទ្រ ។

## ក. ការគ្រប់គ្រងវារីវប្បកម្មទឹកសាប

តាមមាត្រា ៥៣ នៃច្បាប់ស្តីពីជលផល: ការធ្វើវារីវប្បកម្មទឹកសាបអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលជាមុន បើការចិញ្ចឹមនោះ :

- ស្រះចិញ្ចឹមមានផ្ទៃក្រឡាសរុបលើស ៥.០០០ ម៉ែត្រការ៉េ
- ស៊ងចិញ្ចឹមមានផ្ទៃក្រឡាសរុបលើស ២.០០០ ម៉ែត្រការ៉េ
- បែចិញ្ចឹមមានផ្ទៃក្រឡាសរុបលើស ១៥ ម៉ែត្រការ៉េ

ដោយឡែក ការធ្វើវារីវប្បកម្មក្រពើ កន្ធាយ អណ្តើក កង្កែប ពស់ដែលបង្កកំណើតក្នុងទឹក ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ខ. ការគ្រប់គ្រងវារីវប្បកម្មសមុទ្រ

តាមមាត្រា ៥៤ នៃច្បាប់ស្តីពីជលផល: ការធ្វើវារីវប្បកម្មសមុទ្រអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលជាមុន បើការចិញ្ចឹមនោះ :

- បែចិញ្ចឹមមានផ្ទៃក្រឡាសរុបលើស ២០ ម៉ែត្រការ៉េ
- ស្រែបង្គាចិញ្ចឹមមានផ្ទៃក្រឡាសរុបលើស ៥.០០០ ម៉ែត្រការ៉េ
- វារីរុក្ខជាតិគ្រប់ប្រភេទមានផ្ទៃក្រឡាលើស ៥.០០០ ម៉ែត្រការ៉េ
- វារីសត្វគ្រប់ប្រភេទមានផ្ទៃក្រឡាលើស ៣.០០០ ម៉ែត្រការ៉េ

ដោយឡែក ការធ្វើវារីវប្បកម្មអណ្តើកសមុទ្រ ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ២.ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល

ការដឹកជញ្ជូនផលិតផលជលផល ដែលមានលក្ខណៈពាណិជ្ជកម្មនៅក្នុងប្រទេស ច្បាប់ស្តីពីជលផលតម្រូវឱ្យសុំលិខិតអនុញ្ញាតពីរដ្ឋបាលជលផលជាមុន ( មាត្រា ៦៤ ច្បាប់ស្តីពីជលផល) ។ ដោយឡែក ការនាំចូលនាំចេញនូវផលិតផលជលផល ដែលមានលក្ខណៈពាណិជ្ជកម្ម អ្នកដឹកជញ្ជូន ឬ ពាណិជ្ជករ ត្រូវមានលិខិតអនុញ្ញាត និងកាតព្វកិច្ចមួយចំនួនដូចខាងក្រោម:

**ចំពោះការនាំចេញ:**

- លិខិតអនុញ្ញាតពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល
- លិខិតអនុញ្ញាតនាំចេញពីអាជ្ញាធរសាយតេសនៃកម្ពុជា
- វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល

**ចំពោះការនាំចូល:**

- លិខិតអនុញ្ញាតអំពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល
- លិខិតអនុញ្ញាតឱ្យនាំចេញពីអាជ្ញាធរគ្រប់គ្រងសាយតេសនៃប្រទេសនាំចេញ ចំពោះប្រភេទផលិតផល ជលផល ដែលកំពុងរងគ្រោះថ្នាក់ ទោះពុំមានលក្ខណៈពាណិជ្ជកម្មក៏ដោយ
- វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផលរបស់ប្រទេសនាំចេញ ( មាត្រា ៦៧ ច្បាប់ដដែល)

គ្រប់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដឹកជញ្ជូននូវផលិតផល ជលផលមានលក្ខណៈពាណិជ្ជកម្ម ត្រូវបង់ថ្លៃបុព្វលាភលើការដឹកជញ្ជូននេះបន្ថែមទៀត មាត្រា ៦៥ ច្បាប់ដដែល ) ។

## ៣. អំពីបរិស្ថាន ការនាំចូលវារីវុក្ខជាតិ វារីសត្វពីបរទេស និងការចេញលិខិតអនុញ្ញាត

### ក. អំពីបរិស្ថាន

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលធ្វើវារីវប្បកម្មគ្រប់ប្រភេទ ត្រូវរក្សាគុណភាពដី ទឹក វារីជីវសាស្ត្រ បរិស្ថាន និងមិនឱ្យសារធាតុពុល កាកសំណល់រឹង រាវ ឬ សកម្មភាពផ្សេងៗចូលក្នុងដែននេសាទ ( មាត្រា ២២មាត្រា ៥៧ ច្បាប់ស្តីពីជលផល) ។

### ខ. ការនាំចូលវារីរុក្ខជាតិ វារីសត្វពីបរទេស

ចំពោះការនាំចូលវារីរុក្ខជាតិ វារីសត្វគ្រប់ប្រភេទពីបរទេស ត្រូវមានការត្រួតពិនិត្យគុណភាពដោយធ្វើការពិសោធន៍ និង វាយតម្លៃលើគំរូសំណាកដោយមន្ទីរពិសោធន៍របស់រដ្ឋបាលជលផល ( មាត្រា ៥៥ ច្បាប់ស្តីពីជលផល) ។ ដោយឡែក ការធ្វើវារីវប្បកម្មត្រីលំអគ្រប់ប្រភេទ ក្នុងលក្ខណៈធ្វើអាជីវកម្ម ត្រូវមានលិខិតអនុញ្ញាតអំពីរដ្ឋបាលជលផលជាមុនដែរបើការធ្វើវារីវប្បកម្មនោះ :

- វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ប្រភេទត្រីលំអពូជក្នុងប្រទេសលើសពីមួយម៉ឺន (១០.០០០) ក្បាល
- វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ប្រភេទត្រីលំអពូជក្រៅប្រទេសលើសពីប្រាំពាន់ (៥.០០០) ក្បាល

ត្រីលំអពូជគ្រប់ប្រភេទ ត្រូវកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ៥៥ ) ។

## ឥ. ការចេញលិខិតអនុញ្ញាត

គំរូបែបបទ ព្រមទាំងលិខិតអនុញ្ញាតដែលដាក់ឱ្យប្រើប្រាស់ក្នុងវិស័យជលផល និងការបែងចែកសិទ្ធិទទួលខុសត្រូវលើការចេញលិខិតអនុញ្ញាត ត្រូវកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ៧០ និង ៧១ ច្បាប់ដដែល) ។

## ជំពូក ៤

# នីតិវិធីដោះស្រាយបទល្មើសជលផល

នីតិវិធីដោះស្រាយបទល្មើសជលផល គឺជាកន្សោមពាក្យមួយដែលមានន័យគ្រប់គ្រាន់ និងកើតឡើងពីការផ្សំពាក្យ នីតិវិធី + ដោះស្រាយ + បទល្មើសជលផល ដែល:

នីតិវិធី = បែបបទ ឬ របៀបចាត់ការតាមផ្លូវច្បាប់ (នីតិ=ច្បាប់ . វិធី=បែបបទ ឬ របៀបចាត់ការ)

ដោះស្រាយ = គឺជាដំណោះស្រាយ ឬ ការស្រាយនូវបញ្ហាអ្វីមួយ

បទល្មើសជលផល = គឺជាបទល្មើសព្រហ្មទណ្ឌពិសេសមួយដែលទាក់ទងទៅនឹងធនធានជលផល ។

ដូច្នេះ នីតិវិធីដោះស្រាយបទល្មើសជលផល គឺជា *"វិធី ឬ បែបបទដែលត្រូវដោះស្រាយតាមផ្លូវច្បាប់នៃបទល្មើសព្រហ្មទណ្ឌពិសេស ហើយដែលទាក់ទងទៅនឹងធនធានជលផល ដូចមានចែង និងផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល"* ។

ច្បាប់ស្តីពីជលផល ផ្តល់ការដោះស្រាយបទល្មើសជលផលជា ២ ដំណាក់ការគឺ: ដំណោះស្រាយដំណាក់ការរដ្ឋបាលជលផល ( ១ ) និងដំណោះស្រាយដំណាក់ការតុលាការ ( ២) ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធ និងការអនុវត្តសាលក្រម ឬ សាលដីកា តុលាការ ( ៣ ) ។

## ១. ដំណោះស្រាយបទល្មើសជលផលដោយរដ្ឋបាលជលផល

ដំណោះស្រាយបទល្មើសជលផលក្នុងដំណាក់ការរដ្ឋបាលជលផល គឺជាប្រភេទបទល្មើសជលផលដែលកើតឡើងមានលក្ខណៈមិនធ្ងន់ធ្ងរ ឬ ជាបទល្មើសជលផលដែលបង្កឱ្យប៉ះពាល់ដល់ធនធានជលផលតិចតួច ហើយមិនតម្រូវឱ្យឆ្លងកាត់ស្ថាប័នតុលាការឡើយ ។

មាត្រា ៨៧ នៃច្បាប់ស្តីពីជលផល អនុញ្ញាតឱ្យរដ្ឋបាលជលផលធ្វើការសម្រេចពិន័យអន្តរការណ៍លើមាត្រាចំនួន ៦ គឺ: មាត្រា ៩២.៩៣.៩៤.៩៥.៩៦ និងមាត្រា ៩៧ ។ មាត្រា ៨៧ ដដែលបានកំណត់ប្រាក់ពិន័យអន្តរការណ៍ត្រូវផ្អែកលើ:

-ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស

-កម្រិតខូចខាតដល់បរិស្ថាន

-ចំនួននៃការប្រព្រឹត្តបទល្មើស

-បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល

-ការប្រព្រឹត្តល្មើសដោយចេតនា

ប្រាក់ពិន័យនេះ ត្រូវយោងតាមតម្លៃទីផ្សារជាក់ស្តែងនៃវត្ថុតាង ដោយគុណ ២ ដង ទៅ ៣ដង ឬ តាមការកំណត់

របស់ច្បាប់ ជាអាទិ៍: មាត្រា ៩៦ ត្រូវពិន័យប្រាក់ចាប់ពី ៥.០០០.០០០ រៀល ទៅ ១០.០០០.០០០រៀល និងមាត្រា ៩៧ ត្រូវពិន័យជាប្រាក់ចាប់ពី ៥០០.០០០រៀល ទៅ ៥.០០០.០០០រៀល ឯវត្ថុតាងត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។ ប៉ុន្តែ បើការប្រព្រឹត្តនោះធ្វើឡើងនៅពេលយប់ ឬ មិនរាងចាល ការពិន័យអន្តរការណ៍ត្រូវកើនទ្វេដង និងវត្ថុតាងត្រូវរឹបអូសជាសម្បត្តិរដ្ឋ។ ប៉ុន្តែ មាត្រា ៨៥ ច្បាប់ដដែលបញ្ញត្តិថា បើបុគ្គលណាមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច មានសិទ្ធិប្ដឹងតាមឋានានុក្រម ឬ ទៅតុលាការបាន។

## ១.១. អំពីមន្ត្រីនគរបាលយុត្តិធម៌ជលផល

មន្ត្រីនគរបាលយុត្តិធម៌ជលផល គឺជាមន្ត្រីនគរបាលយុត្តិធម៌ដែលច្បាប់បានប្រគល់សិទ្ធិឱ្យធ្វើការងារយុត្តិធម៌ជាអាទិ៍: ការងារអធិការកិច្ច ការស៊ើបអង្កេត ការស្រាវជ្រាវ ការបំពេញសំណុំរឿងព្រហ្មទណ្ឌជលផល រួមទាំងការចូលរួមសវនាការ និងការអនុវត្តសាលក្រម ឬ សាលដីកាតុលាការថែមទៀតផង។

មាត្រា ៣៦ ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មស្ដីពីច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០២ បញ្ញត្តិថា : ចាត់ទុកជា *មន្ត្រីនគរបាលយុត្តិធម៌ ឬ អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌រួមមាន:*

១. ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត " ក្នុងការកិច្ចតែប៉ុណ្ណោះ "

២. អភិបាល អភិបាលរងខេត្ត/ក្រុង អភិបាល អភិបាលរងស្រុក/ខណ្ឌ និងមេឃុំ/ចៅសង្កាត់

៣. ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកនៃ:

-នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

-នាយកដ្ឋាននគរបាលសេដ្ឋកិច្ច

-នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ

-នាយកដ្ឋានប្រឆាំងភេរវកម្ម

-នាយកដ្ឋាននគរបាលព្រហ្មដែន " ចំពោះបទល្មើសឆ្លងដែន "

-នាយកដ្ឋានជនបរទេស

-មន្ទីរប្រឆាំងគ្រឿងញៀន

៤. ស្នងការ ស្នងការរងនគរបាលខេត្ត/ក្រុង

៥. ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត/ក្រុង ដូចជា :

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម

-ការិយាល័យជនបរទេស

៦. អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក/ខណ្ឌ

៧. ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ "

៨.ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ/សង្កាត់ ចំពោះបទល្មើសព្រហ្មទណ្ឌ

៩. មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រីចាប់ពីអនុប្រធានផ្នែកឡើងនៃកងរាជអាវុធហត្ថដែលទទួលការងារព្រហ្មទណ្ឌ " ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងកិច្ចការយោធា "

*១០.មន្ត្រីនៃក្រសួង ឬ ស្ថាប័នណាដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើស*

ជាគោលការណ៍ ដើម្បីចៀសវាងសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌បំពេញកិច្ចការត្រួតគ្នា មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកជំនាញនិមួយៗ ត្រូវធ្វើសច្ចាប្រណិធានចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បន្ថែមទៀត ។

មាត្រា ៧៣ នៃច្បាប់ស្តីពីជលផល បញ្ញត្តិថា មន្ត្រីរដ្ឋបាលជលផលឱ្យសច្ចាប្រណិធាន ចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីទទួលមុខងារជាមន្ត្រីនគរបាលយុត្តិធម៌។ មាត្រា ៧៧ ច្បាប់ស្តីពីព្រៃឈើ បញ្ញត្តិថាមន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ដោយឡែកមាត្រា ៧៥ និង ៧៦ ច្បាប់ស្តីពីជលផល បានអនុញ្ញាតឱ្យមន្ត្រីរដ្ឋបាលជលផលដែលពុំបានទទួលនីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិមួយចំនួនដែរដូចជា: ការត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម ការដឹកជញ្ជូន មធ្យោបាយដឹកជញ្ជូន ផែត្រី កន្លែងកែច្នៃ កន្លែងធ្វើសន្និធិ ទីតាំងទិញ លក់ សាកសួរព័ត៌មាន ឬ ឃាត់ទុកជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាត ករណីអ្នកកាន់កាប់លិខិតនេះប្រព្រឹត្តបទល្មើសជលផល។

## ១.២. ការចងក្រងសំណុំរឿងសម្រាប់វិវិធិ៍យអន្តរការណ៍ :

ក្នុងពេលប្រត្តិបត្តិការជួបប្រទះបទល្មើសជលផល មន្ត្រីនគរបាលយុត្តិធម៌ជលផល ត្រូវចាប់ផ្តើមធ្វើកំណត់ហេតុនៃអំពើល្មើសជាក់ស្តែង និងព្រឹត្តប័ត្រព័ត៌មានភ្លាម (ចំពោះព្រឹត្តិប័ត្រព័ត៌មានអាចសរសេរបាន ករណីវត្តមានជនល្មើសនៅកន្លែងកើតហេតុ)។

## ក. អំពីកំណត់ហេតុនៃអំពើល្មើសជាក់ស្តែង

កំណត់ហេតុនៃអំពើល្មើសជាក់ស្តែង ត្រូវសរសេរភ្លាមនៅនឹងកន្លែងដែលបទល្មើសកើតឡើង និងច្បាស់លាស់ គ្មានការកោសលុប ឬ សរសេរជួសបានឡើយ។ ការសរសេរត្រូវបំពេញតាមចំណុចដែលបានទុកចន្លោះក្នុងគំរូស្រាប់ ដូចមានក្នុង

ប្រកាសរួម លេខ ៨៦ កសក-៥០១ និង ៥-២៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៩ របស់ក្រសួងយុត្តិធម៌ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ចំណុចសំខាន់នៃកំណត់ហេតុជាក់ស្តែង គឺត្រូវសរសេរអំពីប្រភេទបទល្មើស ឈ្មោះជនល្មើស ទីកន្លែងប្រព្រឹត្តបទល្មើស ទីកន្លែងកំណើតជនល្មើស.... និងជាពិសេសវត្ថុតាងនៃបទល្មើស។

តាមគោលការណ៍ កំណត់ហេតុជាក់ស្តែងដែលធ្វើរួច មន្ត្រីនគរបាលយុត្តិធម៌ជលផល ត្រូវអានឱ្យជនល្មើសស្តាប់ និងផ្តិតស្នាមមេដៃស្តាំ ។ ចំណែក មន្ត្រីនគរបាលយុត្តិធម៌ជលផល ក៏ត្រូវចុះហត្ថលេខារួមជាមួយអ្នកចូលរួមផងដែរ ក្នុងកំណត់ហេតុនៃអំពើល្មើសជាក់ស្តែងនេះ ។

១. អំពីព្រឹត្តប័ត្រព័ត៌មាន

ព្រឹត្តប័ត្រព័ត៌មាន គឺជាប្រវត្តិរូបរបស់ជនល្មើស ដែលជាព័ត៌មានសម្រាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ជលផលស្គាល់នូវអត្តសញ្ញាណ និងអត្តចរិតជនល្មើស ព្រមទាំងសំណូមពររបស់ជនល្មើស។ ការសរសេរព្រឹត្តប័ត្រព័ត៌មានមិនច្បាស់លាស់ ឬមិនយកចិត្តទុកដាក់អាចធ្វើឱ្យមានផលប្រយោជន៍ដល់ជនល្មើស ពិសេសករណីសំណុំរឿងឡើងដល់តុលាការ។ *ឧទាហរណ៍* ការសរសេរអាយុស្មាន១ ( ជាអនីតិជន )។ តាមការអនុវត្តជាក់ស្តែង ក្រៅអំពីឯកសារទាំងពីរខាងលើ មន្ត្រីនគរបាលយុត្តិធម៌ជលផលបានប្រើឯកសារមួយចំនួនទៀតដូចជា : ពាក្យសុំពិន័យសម្រុះសម្រួល កិច្ចសន្យាឈប់ប្រព្រឹត្តបទល្មើស លិខិតទទួលថែរក្សាទុក កំណត់ហេតុបំផ្លាញវត្ថុតាងចោល ឬ កំណត់ហេតុលែងកូនត្រីជាដើម ។ល។

**កំណត់សម្គាល់**

ផ្អែកតាមសេចក្តីសម្រេចលេខ ០២ ប្រ.ក ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩២ របស់ក្រសួងហិរញ្ញវត្ថុ និង សេចក្តីប្រកាសលេខ ០២ ប្រ.ក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល បានផ្តល់ប្រាក់រង្វាន់ ៥០% ចំពោះអ្នកមានស្នាដៃក្នុងការបង្ក្រាបបទល្មើសដែលបានពិន័យអន្តរការណ៍នេះ។

## ២.ដំណោះស្រាយបទល្មើសជលផលដោយតុលាការ

នេះជាដំណោះស្រាយបទល្មើសជលផលដែលឆ្លងផុតពីសមត្ថកិច្ចជលផលហើយក៏ជាប្រភេទបទល្មើសជលផលដែលជនល្មើសបានប្រព្រឹត្តឡើងមានលក្ខណៈធ្ងន់ធ្ងរ និងទទួលទោសធ្ងន់ធ្ងរទៅតាមកំហុសដែលបានប្រព្រឹត្តផងដែរ ។ ម្យ៉ាងទៀត បទល្មើសប្រភេទនេះ ទោះបីជាមានការព្រមព្រៀងគ្នារវាងជនល្មើស និងរដ្ឋបាលជលផលមានសមត្ថកិច្ចក៏ដោយក៏មិនអាចធ្វើការសម្រុះសម្រួលជាមួយជនល្មើសបានឡើយ គឺសំណុំរឿងនៃបទល្មើសជលផល ដាច់ខាតត្រូវតែបញ្ជូនសំណុំរឿងទៅតុលាការជានិច្ច ។ ក្នុងករណីរដ្ឋបាលជលផលមានសមត្ថកិច្ចមិនអនុវត្តតាម មន្ត្រីរូបនោះនឹងត្រូវទទួលទោសព្រហ្មទណ្ឌតាមមាត្រា ២២ និង មាត្រា ៥៧ ដែលត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ( មាត្រា ៤៧ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣) ។ ករណីនេះ មានន័យថា: ក្រៅពីមាត្រា ៩២.៩៣.៩៤.៩៥.៩៦ និង ៩៧ គឺជាសមត្ថកិច្ចរបស់តុលាការ ។

ប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ។ ប៉ុន្តែច្បាប់ដដែលក៏បានបញ្ជាក់បន្ថែមទៀតថា សេចក្តីសម្រេចតំកល់រឿងទុកមិនចាត់ការនេះ មិនមែនជាសេចក្តីសម្រេចដាច់ខាតនោះទេ មានន័យថា ព្រះរាជអាជ្ញាអាចប្រែប្រួលសេចក្តីសម្រេចនេះបានជាដរាប កុំឱ្យតែផុតអាជ្ញាយុកាល ឬ ករណីផ្សេងទៀតដែលមានចែងក្នុងច្បាប់ ។

**ខ. អំពីចៅក្រមស៊ើបអង្កេត ឬ សុភាចារបុរស**

ចំពោះសំណុំរឿងដែលពុំទាន់មូល ឬ មានលក្ខណៈស្មុគស្មាញ ឬ ជនល្មើសគេចខ្លួនបាត់ ឬ បទល្មើសបង្កឡើងដោយសហចារី និងជនសមគំនិតចូលរួម និងតុលាការមិនអាចធ្វើការជំនុំជំរះបាន ព្រះរាជអាជ្ញា ត្រូវបញ្ជូនសំណុំរឿងព្រហ្មទណ្ឌជលផលនេះមកឱ្យចៅក្រមស៊ើបអង្កេតភ្លាមដើម្បីឱ្យចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតបំពេញសំណុំរឿង( មាត្រា ៦៧ច្បាប់ដដែល) និងបើកសវនការ ។ ដោយឡែក ចៅក្រមស៊ើបអង្កេត ពុំអាចធ្វើការស៊ើបអង្កេតបានទេ ករណីគ្មាន **ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ** អំពីព្រះរាជអាជ្ញាជាមុនទេនោះ ។ តាមប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជានាបច្ចុប្បន្ន ព្រះរាជអាជ្ញា គ្មានសិទ្ធិជ្រើសរើសចៅក្រមស៊ើបអង្កេតតាមចំណង់របស់ខ្លួនឡើយ និងម្យ៉ាងទៀត ព្រះរាជអាជ្ញា ក៏មិនអាចដកសំណុំរឿងដែលខ្លួនបានប្រគល់រួចហើយនោះ ពីចៅក្រមស៊ើបអង្កេតមកវិញបានវិញដែរ នៅពេលដែលចៅក្រមស៊ើបអង្កេត កំពុងធ្វើការស៊ើបអង្កេត ។ ចៅក្រមស៊ើបអង្កេត អាចផ្ទេរសមត្ថកិច្ចរបស់ខ្លួនទៅឱ្យចៅក្រមស៊ើបអង្កេតផ្សេង ឬ មន្ត្រីនគរបាលយុត្តិធម៌ជលផលបានឱ្យតែមានផលប្រយោជន៍សម្រាប់ដាក់បន្ទុកលើជនល្មើស ឬ ក្នុងករណីចៅក្រមស៊ើបអង្កេតជាប់រវល់ការងារច្រើន ហើយមិនអាចបំពេញកិច្ចការនេះបាន ( មាត្រា ៣៨ ថ្មីច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០២) ។ ចៅក្រមស៊ើបអង្កេតមានអំណាច ២ ដែរគឺៈ អំណាចលើកលែងចោទប្រកាន់ និងអំណាចបញ្ជូនរឿងទៅជំនុំជំរះ ។

**អំណាចលើកលែងចោទប្រកាន់ៈ** ចំពោះអំណាចនេះ គឺករណីចៅក្រមស៊ើបអង្កេតពេលធ្វើការស៊ើបអង្កេតទៅ ពិនិត្យឃើញថាបទល្មើសជលផល ដែលព្រះរាជអាជ្ញាបញ្ជូនមកនេះ មិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬ គ្មានបន្ទុកគ្រប់គ្រាន់ ។ ដូចនេះ គាត់សម្រេចធ្វើការលើកលែងចោទប្រកាន់ ។ ប៉ុន្តែអំណាចលើកលែងចោទប្រកាន់នេះ ចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងមកព្រះរាជអាជ្ញាភ្លាមក្នុងរយៈពេល២៤ ម៉ោង ដើម្បីឱ្យព្រះរាជអាជ្ញាប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ( ករណីព្រះរាជអាជ្ញាមិនឯកភាព ) ។ ម្យ៉ាងទៀត សេចក្តីសម្រេចនេះ ចៅក្រមស៊ើបអង្កេតក៏ត្រូវជូនដំណឹងមកដើមបណ្តឹង (រដ្ឋបាលជលផលមានសមត្ថកិច្ច )វិញដែរក្នុងរយៈពេល ៧ ថ្ងៃ ដើម្បីប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ឬ ប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ( មាត្រា ៩០ ថ្មីច្បាប់វិសោធនកម្មនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០២) ។

**កំណត់សម្គាល់:**

ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិទៀតថា គ្រប់សេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត គឺព្រះរាជអាជ្ញាមានសិទ្ធិប្តឹងជំទាស់ជានិច្ច ( មាត្រា ៩៤ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣) ក្នុងករណីមិនឯកភាពនឹងសេចក្តីសម្រេចនេះ ។

**អំណាចបញ្ជូនរឿងទៅជំនុំជំរះៈ** អំណាចនេះ គឺចៅក្រមស៊ើបអង្កេត ពេលធ្វើការស៊ើបអង្កេតទៅ រកឃើញថា ពិតជា

បទល្មើសព្រហ្មទណ្ឌជលផលដូចមានក្នុងសំណុំរឿងចោទប្រកាន់របស់ព្រះរាជអាជ្ញា ហើយសំណុំរឿងមូលចប់សព្វគ្រប់ អាចនឹងជំនុំជំរះបាន។ ករណីនេះ ចៅក្រមស៊ើបអង្កេត ត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាដើម្បីធ្វើការសន្និដ្ឋានស្ថាពរជាមុនសិន មុននឹងបញ្ជូនទៅឱ្យប្រធានតុលាការដើម្បីចាត់តាំងចៅក្រមជំនុំជំរះ ។

### គ. អំពីចៅក្រមជំនុំជំរះ

ចៅក្រមជំនុំជំរះ គឺជាចៅក្រមដែលមានសិទ្ធិសម្រេចសេចក្តីគ្រប់រឿងព្រហ្មទណ្ឌនៅក្នុងសវនាការ ចៅក្រមនេះត្រូវបានតែងតាំងឡើងដោយប្រធានតុលាការ ហើយដែលមិនមែនជាចៅក្រមធ្លាប់ស៊ើបអង្កេតរឿងដដែលនេះទេ ព្រោះថាបើគាត់ជាចៅក្រមស៊ើបអង្កេតផង ហើយក្លាយជាចៅក្រមជំនុំជំរះទៀត ជនល្មើសមិនអាចគេចផុតពីការផ្តន្ទាទោសបានឡើយ ។ (មាត្រា ៦៨ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣) ។

ចៅក្រមជំនុំជំរះ បន្ទាប់ពីបានតែងតាំងរួច ត្រូវពិនិត្យសំណុំរឿងដោយហ្មត់ចត់ និងកំណត់ថ្ងៃជំនុំជំរះដោយខ្លួនឯងដែលតាមធម្មតាគឺ ២០ ថ្ងៃបន្ទាប់ពីទទួលសំណុំរឿង លើកលែងតែសំណុំរឿងមិនទាន់មូលចប់សព្វគ្រប់និងអាចជំនុំជំរះបាន។ ចៅក្រមជំនុំជំរះ ចាំបាច់ត្រូវចាត់តាំងក្រឡាបញ្ជី ១ នាក់ដើម្បីជួយការងារខ្លួនដូចជាៈរៀបចំសំណុំរឿងសម្រាប់ជំនុំជំរះ រៀបចំសាលប្រជុំធ្វើលិខិតអញ្ជើញផ្សេងៗ និងជាពិសេសធ្វើជាអ្នកកត់ត្រាក្នុងពេលសវនការ ។

## ៣.សមត្ថកិច្ចពាក់ព័ន្ធ និងការអនុវត្តសាលក្រម ឬ សាលដីកា ៈ

### ៣.១. សមត្ថកិច្ចពាក់ព័ន្ធ

ច្បាប់ស្តីពីជលផល បានកំណត់ផងដែរនូវសមត្ថកិច្ចមួយចំនួន ត្រូវតែសហការដើម្បីធានាការងារអធិការកិច្ចជលផលឱ្យបានល្អប្រសើរ មានជាអាទ៍ៈ

**-សហគមន៍នេសាទៈ** មាត្រា ១១ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទបញ្ញត្តិថា ៈ សហគមន៍នេសាទត្រូវតែសហការណ៍ជាមួយសមត្ថកិច្ចជលផល ដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ ។ ក្នុងករណីបន្ទាន់និងចាំបាច់ សហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាងដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសរួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផលដើម្បីដោះស្រាយបទល្មើសតាមលក្ខណៈច្បាប់ ។ មាត្រា ២០ នៃអនុក្រឹត្យដដែលក៏បានបញ្ញត្តិទៀតថា ៈ គណៈកម្មការសហគមន៍នេសាទត្រូវរាយការណ៍ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់សមត្ថកិច្ចជលផល ដែលនៅជិតបំផុត ។

**-សមត្ថកិច្ចពាក់ព័ន្ធផ្សេងៗៈ** មាត្រា ៧៤ នៃច្បាប់ដដែលក៏បានតម្រូវឱ្យអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយ និងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ កំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កភាពងាយស្រួលនិងផ្តល់កំលាំងសហការស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ឬ ថែរក្សាវត្ថុតាងបទល្មើសជលផលជា

បណ្តោះអាសន្ន ករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច ។ ប៉ុន្តែច្បាប់បានហាមឃាត់ផងដែរ ការប្រមូលប្រាក់ពិន័យដោយផ្ទាល់ ឬ រឹអូសវត្ថុតាងបទល្មើសជលផលដោយផ្ទាល់ ។ ផ្ទុយទៅវិញ ករណីសមត្ថកិច្ចខាងលើជួយអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬ ប្រយោលដល់ការធ្វើអាជីវកម្មជលផល ឬ ធ្វើសកម្មគ្រប់បែបយ៉ាងផ្ទុយនឹងច្បាប់ស្តីពីជលផល ឬ ធ្វើការ គំរាមកំហែងដល់មន្ត្រីរដ្ឋបាលជលផល ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលជលផល ត្រូវចាត់ទុកជាបទល្មើសនិងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពី ៥ លានរៀល ទៅ ៥០ លានរៀល (មាត្រា ១០២ ច្បាប់ស្តីពីជលផល)។ ដូចគ្នានេះដែរ មន្ត្រីរដ្ឋបាលជលផលណាមួយ ដែលផ្តល់ការអនុញ្ញាតណាមួយផ្ទុយនឹងច្បាប់នេះ ឬ ចូលរួមទាំងស្រុង ឬ ដោយផ្នែក និងដោយផ្ទាល់ ឬ ដោយប្រយោល ក្នុងសកម្មភាពណាមួយដល់ការធ្វើអាជីវកម្មជលផលដែលផ្ទុយនឹងច្បាប់ស្តីពីជលផល ឬ អនុគ្រោះចំពោះបទល្មើសជលផលថ្នាក់ទី ១ ឬ ធ្វើជាម្ចាស់ទាំងស្រុងក្តី ជាភាគហ៊ុនក្តីនៃអាជីវកម្មឡូត៍នេសាទក្នុងកំឡុងពេលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ឬ មិនរាយការណ៍ ឬ មិនដាក់ពាក្យបណ្តឹងអំពីបទល្មើសជលផលដែលកើតមាននៅក្នុងដែនសមត្ថកិច្ចខ្លួន ឬ ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬ ផ្តល់ព័ត៌មានឬរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដើម្បីឱ្យបទល្មើសជលផលថ្នាក់ទី ១ ដែលកើតមានគឺត្រូវមានទោសដូចគ្នានឹងសមត្ថកិច្ចផ្សេងៗ ដូចបានចែងក្នុងមាត្រា ១០២ ច្បាប់ស្តីពីជលផលដែរ ។

### ៣.២. ការអនុវត្តសាលក្រម ឬ សាលដីកា

មាត្រា ១០៥ ច្បាប់ស្តីពីជលផល និងសារាចរលេខ ០២ សរ-៦១៣-៨៨ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៨៨ របស់ក្រសួងយុត្តិធម៌ អនុញ្ញាតឱ្យរដ្ឋបាលជលផលជាអ្នកអនុវត្តសាលក្រម ឬ សាដីកាស្ថាពរតុលាការ លើកលែងទោសពន្ធនាគារ ។

មាត្រា ១០៧ នៃច្បាប់ដដែល ផ្តល់សិទ្ធិឱ្យរដ្ឋបាលជលផលជាអ្នកអនុវត្តការរឹបអូសវត្ថុតាង ការលក់ឡាយឡុងដើម្បីប្រមូលថវិកាបង់ចូលថវិការដ្ឋ ឬ ការបំផ្លាញវត្ថុតាងចោល ។ម្យ៉ាងទៀតមាត្រា៨៧នៃច្បាប់ដដែលអនុញ្ញាតឱ្យមន្ត្រីរដ្ឋបាលជលផលជាអ្នកថែរក្សាទុករាល់វត្ថុតាងដែលបានឃាត់ហូតទុកជាបណ្តោះអាសន្ន អំពីការប្រព្រឹត្តបទល្មើសជលផលរហូតដល់សំណុំរឿងត្រូវបានដោះស្រាយរួចជាស្ថាពរ (ពិន័យអន្តរការណ៍ ឬ តាមការជំនុំជំរះរបសលតុលាការ) ។ ដូចគ្នានេះដែរ មន្ត្រីរដ្ឋបាលជលផលអាចឃាត់ខ្លួនជាបណ្តោះអាសន្ននូវអ្នកបើកបរ អូស ឬ រុញដើម្បីប្រព្រឹត្តបទល្មើសជលផលដែលគ្មានម្ចាស់នៅជាមួយដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសមគំនិត ឬ អាចលក់វត្ថុតាងណាដែលទុកយូរ មិនបានហើយឆាប់ពុកផុយបាត់បង់បរិមាណ ឬ ខូចគុណភាពដើម្បីយកប្រាក់មកតម្កល់ទុក ។

# ឯកសារខ្មែរ

១-ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២

២-ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣

៣-ច្បាប់វិសោធនកម្មមាត្រា ៣៦.៣៨.៩០ និងមាត្រា ៩១ ថ្មីនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០២

៤-ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ឆ្នាំ ២០០៥

៥-អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ ២០០៥

៦-ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦

